**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

*ថ្ងៃ អង្គារ ១០ កើត ខែ ផល្គុន ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣*
*រាជធានីភ្នំពេញ, ថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០២០*

# សេចក្ដីប្រកាសព័ត៌មាន
## ស្ដីពីកិច្ចប្រជុំពិនិត្យ និងពិភាក្សាលើសេចក្ដីព្រាង «អនុក្រឹត្យស្ដីពីការគ្រប់គ្រងការវិនិយោគសាធារណៈ» និងសេចក្ដីព្រាង «ផែនការសកម្មភាពលម្អិត សម្រាប់អនុវត្តយុទ្ធសាស្ត្រស្ដីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ ២០១៩ - ២០២៥»

នាព្រឹកថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០២០, នៅទីស្ដីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (ក.ស.ហ.វ.) បានដឹកនាំកិច្ចប្រជុំថ្នាក់ដឹកនាំក្រសួង ដើម្បីពិនិត្យ និងពិភាក្សាលើឯកសារ ចំនួន ២ គឺ÷ ១. សេចក្ដីព្រាង **«អនុក្រឹត្យស្ដីពីការគ្រប់គ្រងការវិនិយោគសាធារណៈ»** និង ២. សេចក្ដីព្រាង **«ផែនការសកម្មភាពលម្អិតសម្រាប់អនុវត្តយុទ្ធសាស្ត្រស្ដីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ ២០១៩ - ២០២៥»** ។

សេចក្ដីព្រាងឯកសារដ៏មានសារៈសំខាន់ទាំងពីរខាងលើ ត្រូវបានរៀបចំឡើងដោយក្រុមការងារបច្ចេកទេសនៃ ក.ស.ហ.វ. តាមការចង្អុលរបស់យុទ្ធសាស្ត្រស្ដីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ ២០១៩ - ២០២៥ ដែលរាជរដ្ឋាភិបាលបានអនុម័ត កាលពីថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១៩ និងប្រកាសដាក់ឱ្យអនុវត្តនាសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី កាលពីថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៩ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ។ សេចក្ដីព្រាងឯកសារទាំងពីរនេះ ត្រូវបានដាក់ឆ្លងកិច្ចពិភាក្សាកម្រិតបច្ចេកទេសផ្ទៃក្នុង ក.ស.ហ.វ. ជាច្រើនលើកច្រើនសារ និងសិក្ខាសាលាពិគ្រោះយោបល់កម្រិតបច្ចេកទេស ជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍នានា ព្រមទាំងអគ្គនាយកដ្ឋាន/អង្គភាពពាក់ព័ន្ធ ក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រួចរាល់ហើយ មុននឹងយកមកពិនិត្យពិភាក្សា និងសម្រេចនាថ្ងៃនេះ ។

ជារួម, **«អនុក្រឹត្យស្ដីពីការគ្រប់គ្រងការវិនិយោគសាធារណៈ»** មានគោលដៅកំណត់គោលការណ៍ជាសារវន្ត និងប្រព័ន្ធនៃការគ្រប់គ្រងការវិនិយោគសាធារណៈ ជាអាទិ៍ រួមមាន÷

១. គោលការណ៍រួមសម្រាប់គ្រប់គ្រងគម្រោងវិនិយោគសាធារណៈពីគ្រប់ប្រភពហិរញ្ញប្បទាន និងនៅគ្រប់កម្រិតរដ្ឋបាល,

២. គុណភាព ប្រសិទ្ធភាពអនុវត្ត និងភាពផ្សារភ្ជាប់រវាងផែនការវិនិយោគសាធារណៈ ជាមួយនឹងថវិកានីយកម្មការវិនិយោគសាធារណៈ,

៣. ដំណាក់កាលរួមនៃវដ្តគម្រោងវិនិយោគសាធារណៈ,

៤. តួនាទី និងភារកិច្ចរបស់ក្រសួង-ស្ថាប័ន នៅគ្រប់ដំណាក់កាលនៃវដ្តគម្រោង,

៥. នីតិវិធីនៃការរៀបចំ និងគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ នៅគ្រប់ ដំណាក់កាលនៃវដ្តគម្រោង, និង

៦. កាតព្វកិច្ចនៃការរៀបចំរបាយការណ៍ ។

ដោយឡែក, **«ផែនការសកម្មភាពលម្អិតសម្រាប់អនុវត្តយុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ ២០១៩ - ២០២៥»** គឺជាឧបករណ៍ជំនួយក្នុងការត្រួតពិនិត្យ, តាមដាន, និងវាយតម្លៃលើវឌ្ឍនភាពនៃការអនុវត្តយុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ ២០១៩ - ២០២៥ ប្រចាំត្រីមាស និងប្រចាំឆ្នាំ ដែលកំណត់ច្បាស់លាស់អំពី÷ សូចនាករសមិទ្ធកម្មគន្លឹះ, ក្របខ័ណ្ឌពេលវេលាអនុវត្ត, និងអង្គភាពទទួលខុសត្រូវ ។

ជាទីបញ្ចប់, ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានអង្គប្រជុំ បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះមតិយោបល់ល្អៗ របស់សមាជិក សមាជិកា នៃអង្គប្រជុំ ព្រមទាំងបានវាយតម្លៃខ្ពស់ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ក្រុមការងារបច្ចេកទេសនៃ ក.ស.ហ.វ. ដែលបានរៀបចំសេចក្តីព្រាងឯកសារដ៏មានសារៈសំខាន់ទាំងពីរនេះ ។